00407725

D97/17/1

នៅចំពោះមុខអង្គបុរេជំនុំជម្រះ

នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧/អវតក/អបជ |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០ |
| ភាគីអ្នកដាក់: | មេធាវីដើមបណ្តឹងរដ្ឋប្បវេណី |
| ភាសាដើម: | បារាំង (បកប្រែជាភាសាខ្មែរ) |

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / JAN / 2010
ម៉ោង (Time/Heure): 13:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.ចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / JAN / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

---

# សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចអនុវត្តបាននៃទម្រង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម

---

| អ្នកដាក់ឯកសារ | អ្នកទទួលឯកសារ |
|---|---|
| **មេធាវីដើមបណ្តឹងរដ្ឋប្បវេណី** | **ចៅក្រមអង្គបុរេជំនុំជម្រះ:** |
| លោក គឹម ម៉េងឃី | លោក ប្រាក់ គឹមសាន (ប្រធាន) |
| កញ្ញា ម៉ុច សុវណ្ណារី | លោក ន័យ ធុល |
| លោកស្រី Elisabeth RABESANDRATANA | លោក ហួត វុទ្ធី |
| លោក Philippe CANNONE | លោកស្រី Katinka LAHUIS |
| លោកស្រី Martine JACQUIN | លោក Rowan DOWNING |

00407726

លោកស្រី Annie DELAHAIE

លោកស្រី Fabienne TRUSSES-NAPROUS

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew T. Cayley

លោក William SMITH

លោក ពេជ្រ សម្បត្តិ

**ជនត្រូវចោទ**

នួន ជា

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីការពារក្ដី**

លោក សុន អរុណ លោក Michiel PESTMAN

លោក ស ស្វរាន លោក Jacques VERGES

លោក អាង ឧត្តម លោកMichael G.KARNAVAS

លោក ផាត់ ពៅស៊ាង អ្នកស្រី Diana ELLIS

**ភាគីដើមបណ្ដឹងរដ្ឋប្បវេណី**

**លោក នី ច័ន្ទឌី លោក ឡោ ឈុនធី លោក គង់ ពិសី**

**លោក ហុង គីមសួន លោក យុង ផានិត លោកស្រី**

**ស៊ីន សុវន លោកស្រី ជេត វណ្ណលី លោក ពេជ អង្គ**

កញ្ញា SILKE Stundzinsky **លោក** Pierre-Olivier

SUR , Mahdev MOHAN, Olivier BAHOUGNE
David BLACKMAN, Patrick BAUDOIN,
Lyma Thuy Nguyen, Marie Guiraud

## I. រំលឹកអំពីខ្លឹមហេតុ និង នីតិវិធី

1. ដើម្បីបង្ហាញពីអង្គហេតុនានា យើងនឹងយោងទៅដល់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៧ និងជាក់ច្បាស់ជាងនេះទៅទៀត ពីអង្គហេតុដែលបានបង្ហាញក្នុងកថាខណ្ឌទី ៣៧ ដល់ ៧២ ដែលទាក់ទងនឹងបទចោទដូចខាងក្រោម៖

ក. អំពើមនុស្សឃាត (កថាខណ្ឌ ៤៩-៧២) ការធ្វើទារុណកម្ម (កថាខណ្ឌ ៤៩-៧២) ការធ្វើទុកបុកម្នេញចំពោះពុទ្ធសាសនិក និង ជនជាតិចាម (កថាខណ្ឌ ៣៧-៧២) ។ អំពើទាំងនេះចាត់ទុកជាការរំលោភទៅនឹងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ (មាត្រា ៥០១ ៥០៣ ៥០៤ ៥០៥ ៥០៦ ៥០៧ និង ៥០៨) មាត្រា ៥០០ និង ២០៩ និង ២១០ ដែលត្រូវគ្នានឹងមាត្រា ៣ (ថ្មី) ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

ខ. អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងពុទ្ធសាសនិក សាសនិកឥស្លាម និង ជនជាតិវៀតណាម (កថាខណ្ឌ ៣៧-៧២) ។ អំពើទាំងនេះ ចាត់ទុកជាការរំលោភលើសន្ធិសញ្ញាអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការ និង ការបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវគ្នានឹងមាត្រា ៤ ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

គ. អំពើមនុស្សឃាតដោយចេតនា (កថាខណ្ឌ ៤៩-៧២) ការសម្លាប់រង្គាល (កថាខណ្ឌ ៤៩-៧២) ការធ្វើឱ្យក្លាយជាទាសករ (កថាខណ្ឌ ៤៣-៤៨) ការជម្លៀស (កថាខណ្ឌ ៣៧-៤២) ការឃុំឃាំង (កថាខណ្ឌ ៤៣-៧២) ការធ្វើទារុណកម្ម (កថាខណ្ឌ ៤៩-៧២) ការធ្វើទុកបុកម្នេញខាងនយោបាយ ជាតិសាសន៍ និង សាសនា ចំពោះអតីតអ្នកទទួលខុសត្រូវក្នុងរបបសាធារណៈខ្មែរ សមាជិកនៃពួកគហបតី ពួកមូលធន និង ពួកអភិជន “ប្រជាជនថ្មី” ដែលគេចាត់ទុកថាជា “សមាសភាពមិនល្អ” ពុទ្ធសាសនិកជន ជនជាតិចាម និងជនជាតិវៀតណាម និង អំពើអមនុស្សធម៌ផ្សេងទៀត (កថាខណ្ឌ ៣៧-៧២) ។ អំពើទាំងនេះចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវគ្នានឹងមាត្រា ៥ មាត្រា២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

ឃ. អំពើមនុស្សឃាតដោយចេតនា (កថាខណ្ឌ ៤៩-៧២) ការធ្វើទារុណកម្ម ឬអំពើអមនុស្សធម៌ (កថាខណ្ឌ ៤៩-៧២) អំពើដែលបង្ករមានការរងទុក្ខវេទនា ឬបង្ករឱ្យប៉ះពាល់ដល់បូរណភាពរាងកាយ ឬដល់សុខភាព (កថាខណ្ឌ ៤៩-៧២) ការបំផ្លាញ ឬការធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិ ដែលមិនបានបង្ហាញពីភាពចាំបាច់ខាងយោធា និង ការសម្លាប់

ថ្នាក់លើដោយខុសច្បាប់និងដោយបំពាន (កថាខណ្ឌ ៣៧-៧២) អំពើនៃការដកហូតសិទ្ធិរបស់អ្នកទោសសង្គ្រាម ឬជនស៊ីវិល ក្នុងការទទួលបាននូវការវិនិច្ឆ័យដោយទៀងទាត់និងយុត្តិធម៌ (កថាខណ្ឌ ៣៧-៧២) និងការជម្លៀស ឬការបញ្ជូនមនុស្សពីកន្លែងមួយទៅកន្លែងមួយដោយខុសច្បាប់ ឬការឃុំជនស៊ីវិលដោយខុសច្បាប់ (កថាខណ្ឌ ៣៧-៧២) ។ អំពើទាំងនេះចាត់ទុកថាជាការរំលោភដ៏ធ្ងន់ធ្ងរលើសន្ធិសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ ដែលត្រូវនឹងមាត្រា ៦ មាត្រា២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ។

2. យោងតាមសារណាចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ អៀង សារី បានប្តឹងសហចៅក្រមស៊ើបអង្កេតចំពោះការស្នើសុំ ដែលក្នុងនោះគាត់បានជំទាស់ទៅលើទំរង់នៃការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ដែលបន្តទៅទៀតនេះត្រូវហៅថា ECC (Entreprise Criminelle Commune) ដែលប្រឆាំងទៅនឹងគាត់ ដែលលើកឡើងពីអសមត្ថកិច្ចរបស់អ.វ.ត.ក នៅក្នុងបញ្ហានេះ ។

3. អៀង ធីរិទ្ធ បានចូលរួមនៅក្នុងការស្នើសុំនេះ ប៉ុន្តែក្នុងនាមបន្ទាប់បន្សំដែលកត់សំគាល់តែទៅលើប្រភេទទីមួយនៃ ECC ដែលអាចលើកឡើងពីសមត្ថកិច្ចរបស់អ.វ.ត.ក ។

4. នៅក្នុងចម្លើយរបស់គាត់ សហព្រះរាជអាជ្ញាស្នើសុំថាសហចៅក្រមស៊ើបអង្កេតយកទំរង់ទាំងបីរបស់ ECC មកអនុវត្តនៅចំពោះមុខអ.វ.ត.ក។ ចំពោះនិយមន័យនៃទំរង់ទាំងបីរបស់ ECC យើងនឹងយោងទៅដល់និយមន័យនៅដីការបស់សហចៅក្រមស៊ើបអង្កេត ។

5. តាមរយៈដីកាចុះថ្ងៃទី០៨ខែធ្នូឆ្នាំ២០០៩ សហចៅក្រមស៊ើបសួរបានសម្រេចដូចតទៅ:

ដោយយល់ឃើញថាទំរង់នៃទំនួលខុសត្រូវក្នុងECC មិនត្រូវបានអនុវត្តចំពោះបទឧក្រិដ្ឋជាតិ គឺអនុវត្តបានតែចំពោះឧក្រិដ្ឋកម្មអន្តរជាតិ:

- យើងធ្វើការច្រានចោលនូវសារណាដែលទាមទារថា ធាតុសំភារៈនិង ធាតុអត្តនោមត្តិរបស់ECC ទំរង់ទីមួយ ត្រូវអនុវត្តចំពោះមុខអ.វ.ត.ក។
- យើងធ្វើការច្រានចោលនូវសារណាដែលទាមទារថា ធាតុសំភារៈនិងធាតុអត្តនោមត្តិរបស់ ECC ទំរង់ទីពីរ ត្រូវអនុវត្តចំពោះមុខអ.វ.ត.ក។
- យើងធ្វើការច្រានចោលនូវសារណាទាំងឡាយដែលទាមទារថា ធាតុសម្ភារៈរបស់ECC ទំរង់ទីបីត្រូវអនុវត្តចំពោះមុខ អ.វ.ត.ក។

- ទទួលយកមួយផ្នែកនៃសារណាដែលទាមទារថា ធាតុអត្តនោមត្តិរបស់ECCទំរង់ទីបី ត្រូវអនុវត្តនៅចំពោះមុខអ.វ.ត.ក តែក្នុងករណីដែលមានការទទួលយល់ព្រមជាលក្ខណៈ អត្តវិស័យនូវវិបាកទាំងឡាយដែលកើតមាន ព្រមទាំងការគ្រោងទុកជាមុននូវការរៀបចំ គោលបំណងជាសមូហភាពមួយ។

6. ដីកាសម្រេចនេះគួរទទួលនូវការរិះគន់ ដែលធ្វើអោយមានមូលដ្ឋាននៃការប្តឹងឧទ្ធរណ៍ ដោយយោង ទៅលើមូលហេតុដូចខាងក្រោមនេះ

II-**លើធាតុនីត្យានុកូល** (NULLUM CRIMEN SINE LEGE)

7. ដីកាសម្រេចដែលគួរចោទប្រកាន់នេះ រក្សាទុកនូវវត្តមានធាតុនីត្យានុកូលដែលយើងអាចដឹងថាជា ការដាក់អោយអនុវត្ត នូវច្បាប់ទំនៀមទំលាប់អន្តរជាតិ មុនអត្ថិភាពនៃអង្គហេតុដែលនឹងត្រូវការពារ មិនឲ្យកើតមានឡើង (កំឡុងពេលថ្ងៃទី១៧មេសាឆ្នាំ១៩៧៥-៧ មករា ឆ្នាំ១៩៧៩) ដើម្បីឲ្យមានមូលដ្ឋានក្នុងច្បាប់អន្តរជាតិ ដើម្បីដាក់អោយមានការអនុវត្ត នូវសញ្ញាណនៃECC ជាពិសេសគឺការអនុវត្តន៍ ECCទំរង់ទីបី មានន័យថាទំរង់ដែលមានវិសាលភាព។ ដីកានេះ បានសំអាងលើលក្ខន្តិកៈនៃមាត្រា១៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចុះ ឆ្នាំ១៩៦៦ និងបានយកសំអាងហេតុរបស់ដីកា Ojdanié ប្រកាសដោយសាលាឧទ្ធរណ៍ TPIY ធ្វើ ជាមូលដ្ឋាននៃការសម្រេចរបស់ខ្លួន។

8. តែផ្ទុយទៅវិញ ដីកានេះបែរជាបដិសេធនូវភាពដែលអាចអនុវត្តបានរបស់ECC ពាក់ព័ន្ធនឹង ឧក្រិដ្ឋកម្មជាតិ នៅក្នុងពេលដែលច្បាប់ព្រហ្មទណ្ឌដែលត្រូវអនុវត្តចំពោះអង្គហេតុនេះដែលបាន កើតឡើងនៅពេលនោះ ជាក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ ក្រមនេះមានចែងបញ្ជាក់អំពី សញ្ញាណនៃសហអំពើ សហចារីដែលផ្សាភ្ជាប់គ្នា ជាមួយអត្ថិភាពនៃការព្រមព្រៀងគ្នាដោយ និង សញ្ញាណនៃការផ្សំគំនិត ដែលបង្ហាញអោយឃើញតាមរយៈការជួយឬការចូលដៃ៖ គឺជាទំរង់ពីរ ប្រភេទនៃការចូលរួមក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលក្នុងនោះមួយ គឺជាការចូលរួមដោយផ្ទាល់ និង មួយទៀតគឺជាការចូលរួមដោយប្រយោល ដូចមានចែងក្នុងមាត្រា៨២ និងមាត្រា១៤៥នៃក្រម ព្រហ្មទណ្ឌឆ្នាំ១៩៥៦។

00407730



9. យើងត្រូវតែយល់ផងដែរថា ច្បាប់នេះបានទទួលរងនូវឥទ្ធិពល ពីច្បាប់ព្រហ្មទណ្ឌបារាំងកាលពីសម័យនោះ (មាត្រា៥៩ និង៦០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៨១០ បានចែងដូចគ្នានូវការបែងចែករវាងសហចារីនិងអ្នកសមគំនិត និងបានគាំទ្រប្រភេទនៃការចូលរួមប្រព្រឹត្តបទឧក្រិដ្ឋ ដែលបានអនុម័តដោយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

10. យើងអាចសន្និដ្ឋានបានថា ទំរង់នៃការទទួលខុសត្រូវក្នុងនាមECC មានចែងរួចជាស្រេចក្នុងច្បាប់កម្ពុជាក្នុងឆ្នាំ១៩៥៦ ក្រោមពាក្យថា"សហអំពើ និងការផ្សំគំនិត" ហើយយ៉ាងហោចណាស់បានរួមបញ្ចូលគ្នា នូវទំរង់ពីរដំបូងរបស់ECCផងដែរ (ទំរង់ទីពីរមានឈ្មោះថា "ជាប្រព័ន្ធ " ដែលជាការកែប្រែបន្ថែមលើទំរង់ទីមួយ)។

11. នៅក្នុងច្បាប់កម្ពុជាមិនមានប្រព័ន្ធយុត្តាធិការស្វយ័តជាក់លាក់ចំពោះបទឧក្រិដ្ឋទាំងនេះទេ គឺមិនមានទីកន្លែងសំរាប់អនុវត្តគោលការណ៍នៃការបកស្រាយច្បាប់ ពាក់ព័ន្ធនឹងប្រភេទជាក់លាក់ ដែលបានកំណត់តាមរយៈប្រពៃណីតុលាការរបស់បារាំង ។ ជាដំបូង ឧក្រិដ្ឋកម្មដែលមានលក្ខណៈជាអន្តរជាតិទាំងនេះ ជាឧក្រិដ្ឋកម្មដែលមានលក្ខណៈជាតិ ហើយក៏ជាឧក្រិដ្ឋកម្មដែលត្រូវ បានប្តឹងចោទប្រកាន់ដោយច្បាប់ជាតិ នៅក្នុងនាមជាបទល្មើសជាតិមួយ ជាបទល្មើសដែលមានចារីច្រើននាក់ (សហអំពើរ) មានអ្នកចូលរួមជួយ និងចូលរួមផ្តល់ជំនួយ (បទសមគំនិត)។

12. ក្នុងន័យនេះ ធាតុនីត្យានុកូលនៃទំរង់នៃការទទួលខុសត្រូវនេះ មានវត្តមានផងដែរ សម្រាប់ឧក្រិដ្ឋកម្មក្នុងច្បាប់កម្ពុជា។

13. ដីកាសម្រេចដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ត្រូវតែធ្វើការកែប្រែ នៅត្រង់ចំនុចនេះ។

III-**<u>លើធាតុសម្ភារៈ</u>**

14. ធាតុសម្ភារៈដែលត្រូវមានសំរាប់ECC មានដូចតទៅ៖

   - ពហុបុគ្គល
   - អត្ថិភាពនៃមានគោលបំណងរួមមួយ សំដែងចេញ ឬបង្ហាញឲ្យឃើញដោយការប្រព្រឹត្តិបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់។
   - ការចូលរួមប្រព្រឹត្តិដោយផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ដើម្បីសម្រេចគោលបំណងរួម

15. អង្គហេតុដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿង ត្រូវតែមានការពិនិត្យយ៉ាងត្រឹមត្រូវបំផុតលើធាតុជាសម្ភារៈនៃធាតុមួយៗដែលមាននោះ។ ឧទាហរណ៍៖ ពហុភាពនៃបុគ្គលដែលគេអាចដឹងបានតាមរយៈការអានកំណត់ហេតុនៃកិច្ចប្រជុំថ្នាក់ដឹកនាំ ដូចជាធាតុសម្ភារៈនៃគោលបំណងរួម

ត្រូវបានបង្កើតឡើងដោយលក្ខន្តិកៈរបស់CPK ហើយវត្តមាននៃមជ្ឈិមបក្សរបស់CPK ដែលបានដាក់អោយដំណើរការដោយផ្ទាល់ នូវនយោបាយនានាពាក់ព័ន្ធសន្តិសុខផ្ទៃក្នុងនិងខាងក្រៅ កិច្ចការបរទេស កិច្ចការផ្ទៃក្នុង សុខភាព កិច្ចការសង្គម ការឃោសនានិងការអប់រំឡើងវិញ កិច្ចការរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្សជាដើម។

16. ធាតុសម្ភារៈដែលចាំបាច់ក្នុងការបង្កើតECCនេះ ត្រូវបានបំពេញយ៉ាងត្រឹមត្រូវបំផុតហើយដីកាសម្រេច ត្រូវតែបញ្ជាក់ត្រង់ចំនុចនេះអោយបានច្បាស់។

## IV-ធាតុអត្តនោម័ត

17. ធាតុអត្តនោមត្តិមាននៅក្នុងអង្គហេតុ ក្នុងករណីដែលមានអត្ថិភាពនៃចេតនាបង្ករ " បទឧក្រិដ្ឋជាក់ច្បាស់ " ហើយចេតនានេះ ត្រូវមាននៅក្នុងខ្លួនបុគ្គលគ្រប់គ្នា ធាតុអត្តនោម័តនៅក្នុងទំរង់ទី២ ទាក់ទងនឹងប្រព័ន្ធនៃការប្រព្រឹត្តិអំពើអមនុស្សធម៌ ជនជាប់ចោទមានការយល់ដឹងអំពីប្រភេទនៃប្រព័ន្ធនោះ ហើយមានចេតនានៅក្នុងការចូលរួមឱ្យប្រព័ន្ធនោះមានដំណើរការ។ ចេតនាទុច្ចរិតពិសេសមួយ ត្រូវបានបង្កើតឡើងយ៉ាពិតប្រាកដនៅទីនេះ អ្នកប្រព្រឹត្តិបទឧក្រិដ្ឋនេះបានអនុវត្តវាក្នុងគោលបំណងកម្ទេចសត្រូវ ដើម្បីបង្កើតសង្គមថ្មីមួយជាមួយមនុស្សថ្មី៖ ចេតនាទុច្ចរិតជាក់លាក់នេះមានយ៉ាងពិតនៅគ្រប់តំណាក់កាលនៃការចោទប្រកាន់ អំពើរបស់បុគ្គលទាំងនោះ គឺគោរពទៅតាមផែនការរួមមួយដែលព្រមព្រៀងគ្នា និងភាពខ្លាំងនៃកិច្ចមិនស្របច្បាប់ដែលមិនគួរអត់អោន ។ គោលដៅនិងគំរោងការនៃឧក្រិដ្ឋកម្មរួម ត្រូវបានបង្ហាញអោយឃើញច្បាស់ ហើយគ្រប់អ្នកដឹកនាំម្នាក់ៗ ស្គាល់ពីគោលបំណងនៃឧក្រិដ្ឋកម្មរួមនោះដែរ។

18. ធាតុអត្តនោមត្តិមានក្នុងECCទៅរង់ទីមួយ និងទីពីរ ត្រូវបានបង្កើតឡើងជាស្រេចហើយ ដីកាសម្រេចត្រូវតែបញ្ជាក់អោយបានច្បាស់លើចំណុចនេះ។

19. ចំពោះធាតុចេតនានៃទំរង់ទីបីរបស់ECC យើងត្រូវបញ្ជាក់ឱ្យបានគ្រប់គ្រាន់ថា ការទទួលខុសត្រូវមានមូលដ្ឋានលើ គោលបំណង គោលដៅ ឬគំរោងរួមមួយ ដែលមានលក្ខណៈអាចគ្រោងទុកជាមុនបាន និងអាចប្រើប្រាស់បាន។ លក្ខណៈវិនិច្ឆ័យនៃការដែលអាចប្រើប្រាស់បាន និងគ្រោងទុកជាមុនបាននេះ ត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលនៃរបបនេះដែលមានរយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ និងក្នុងលក្ខណៈជាការិបអូសដោយបំពានយ៉ាងខ្លាំងក្លាមួយ ។ ទំរង់នៃទំនួលខុសត្រូវនេះគឺអាចសំរេចបាននិងអាចគ្រោងទុកជាមុនបាន សម្រាប់ភាគីការពារ តាមរយៈច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក៏ដូចជាក្រមព្រហ្មទណ្ឌកម្ពុជាដែរ ។ ដូចនេះធាតុចេតនា ត្រូវបានចាត់ទុកថាជាធាតុដែល

ជនជាប់ចោទទាំងឡាយ មិនអាចលើកឡើងបាននូវភស្តុតាងដើម្បីបញ្ជាក់ទោះជាក្នុងវិធីណាក៏ដោយ លើកលែងតែ តាមការបង្ហាញបែបសេកមន្តគាថាប៉ុណ្ណោះថា ពួកគាត់មិនស្គាល់កម្មវត្ថុនិងអំពើឧក្រិដ្ឋរបស់អង្គការដែលពួកគាត់បានដឹកនាំនោះ។

**អាស្រ័យហេតុនេះ**

ជារួមមកឧក្រិដ្ឋកម្មរួមនេះ ត្រូវបានចុះនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ក្នុងកំឡុងពេលសមស្របក៏ដូចជាក្នុងច្បាប់ជាតិផងដែរ ។ ឧក្រិដ្ឋកម្មរួមនេះត្រូវតែរក្សាទុកក្នុងរឿងក្តីបច្ចុប្បន្ននេះ ក្រោមទំរង់របស់វាទាំងអស់។

**រក្សាសិទ្ធិគ្រប់យ៉ាង**
**សំរាប់សហមេធាវីដើមបណ្តឹងរដ្ឋវេណី**

ធ្វើនៅភ្នំពេញថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩

**មេធាវី** Elisabeth RABESANDRATANA

**មេធាវី គីម ម៉េងឃី**

**មេធាវី ម៉ុច សុវណ្ណារី**